## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### សារលិខិត
### សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
### ថ្លែងក្នុងឱកាស ទិវាជាតិអាហារូបត្ថម្ភ លើកទី១ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៤
### ក្រោមប្រធានបទ " អាហារូបត្ថម្ភល្អ ដើម្បីជីវិតរស់នៅកាន់តែប្រសើរ "

- សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី
- បងប្អូនជនរួមជាតិ កូនៗ ក្មួយៗ និស្សិត និងកុមារា កុមារីទាំងអស់ ជាទីស្រឡាញ់ !

ក្នុងឱកាសដ៏មហោឡារិកនៃខួបលើកទី១ **ទិវាជាតិអាហារូបត្ថម្ភ ៦ វិច្ឆិកា** ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវមនោសញ្ចេតនារីករាយជាអនេក និងគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំ **ទិវាជាតិអាហារូបត្ថម្ភលើកទី១** និងសូមថ្លែងនូវសារលិខិតថ្វាយនិងប្រគេនព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ ជូនបងប្អូនជនរួមជាតិ ជាពិសេសស្ត្រីៗជាមាតា និងកូនៗ ក្មួយៗ កុមារជាទីស្រឡាញ់ទាំងអស់ អំពីឆន្ទៈនិងបុព្វហេតុរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបន្តលើកកម្ពស់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងជំរុញការចូលរួមរបស់បងប្អូនជនរួមជាតិយើងទាំងអស់ រួមគ្នាលើកកម្ពស់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាសំដៅកែលម្អអាហារូបត្ថម្ភរបស់មាតា និងកុមារ ដើម្បីអភិវឌ្ឍន៍មូលធនមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ ដែលជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ និងភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជាឲ្យកាន់តែល្អប្រសើរឡើង។

ឆ្នាំនេះ **ទិវាជាតិអាហារូបត្ថម្ភ ៦ វិច្ឆិកា** ត្រូវបានប្រារព្ធឡើងជាលើកដំបូង ក្រោមប្រធានបទ "**អាហារូបត្ថម្ភល្អ ដើម្បីជីវិតរស់នៅកាន់តែប្រសើរ**" មានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងពីអាហារូបត្ថម្ភនៅទូទាំងប្រទេស ស្របគ្នាជាមួយនឹងទិវាយល់ដឹងអាហារូបត្ថម្ភពិភពលោក និងស្របពេលដែលបងប្អូនជនរួមជាតិយើងកំពុងចូលរួមសប្បាយ អបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ដែលជាពិធីបុណ្យប្រពៃណីជាតិខ្មែរយើង តែងតែប្រារព្ធធ្វើតាំងពីសម័យបុរាណកាលមក។ ការប្រារព្ធ **ទិវាជាតិអាហារូបត្ថម្ភ ៦ វិច្ឆិកា** នេះ គឺឆ្លើយតបទៅនឹង

ការប្រកាសរបស់ពិភពលោក ដែលបានបញ្ជាក់ថាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ត្រូវបានពិភពលោកទទួលស្គាល់ និងចាត់ទុកថាជាសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ដែលស្ថិតក្រោមសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។ ឈរលើស្មារតីនេះ និងដោយទទួលស្គាល់អំពីសារៈសំខាន់នៃបញ្ហាអាហារូបត្ថម្ភ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ជាពិសេសលើការលើកកម្ពស់អាហារូបត្ថម្ភសម្រាប់មាតានិងកុមារ ហើយបានចាត់ទុកអាហារូបត្ថម្ភជាបញ្ហាអាទិភាពនៅក្នុងគោលនយោបាយការអភិវឌ្ឍសង្គម ដោយដាក់បញ្ចូលទៅក្នុងគោលនយោបាយនិងផែនការយុទ្ធសាស្ត្រនានា ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៤-២០១៨), ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(២០១៤-២០១៨), យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (២០១៤-២០១៨), ផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨, និងយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ។ នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា អាហារូបត្ថម្ភត្រូវបានលើកឡើងនៅក្នុងគោលដៅទី១ "**លុបបំបាត់ភាពក្រីក្រ និងភាពស្រេកឃ្លាន**" ហើយអាហារូបត្ថម្ភ ក៏មានសារៈសំខាន់ផងដែរ ក្នុងការសម្រេចបាននូវគោលដៅផ្សេងៗទៀត នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គឺគោលដៅទី៤ "**កាត់បន្ថយមរណភាពរបស់កុមារ**" និងគោលដៅទី៥ "**កែលម្អសុខភាពមាតា**"។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា សូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនានា និងបងប្អូនជនរួមជាតិទាំងអស់ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការលុបបំបាត់បញ្ហាកង្វះអាហារូបត្ថម្ភនៅក្នុងសហគមន៍ និងខិតខំធ្វើឱ្យមានអាហារូបត្ថម្ភល្អ និងជីវិតរស់នៅកាន់តែប្រសើរ សម្រាប់ស្ត្រីនិងកុមាររបស់យើង ដោយសំដៅធ្វើយ៉ាងណាឲ្យ "**ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាពផ្នែករូបវន្តសង្គម និងសេដ្ឋកិច្ចប្រសើរជាងមុន ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុតដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់**"។

ក្នុងស្មារតីបង្កើនសកម្មភាពអន្តរាគមន៍ ដើម្បីសម្រេចបានចក្ខុវិស័យខាងលើ និងដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល រាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់និងចាត់វិធានការជាច្រើន ក្នុងការលុបបំបាត់បញ្ហាកង្វះអាហារូបត្ថម្ភសម្រាប់ស្ត្រី និងកុមារ។ ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការកែលម្អស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជា

រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ឆ្នាំ២០១៤-២០២០, និងសម្រេចចូលជាសមាជិកទី៥៣ នៃចលនាពង្រីកកិច្ចអន្តរាគមន៍អាហារូបត្ថម្ភពិភពលោក ដែលសម្របសម្រួលដោយ តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ, និងអនុញ្ញាតឲ្យមានការរៀបចំទិវាជាតិអាហារូបត្ថម្ភនេះឡើងជារៀងរាល់ឆ្នាំក្នុងគោលបំណងដើម្បីរួមគ្នាធ្វើអន្តរាគមន៍លើបញ្ហាកង្វះអាហារូបត្ថម្ភ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ដល់បញ្ហាសុខភាព ការលូតលាស់នូវបញ្ញាស្មារតី និងរូបរាងកាយដែលទាំងអស់នេះជាកត្តាកំណត់ដ៏សំខាន់សម្រាប់មនុស្សម្នាក់ៗក្នុងការអភិវឌ្ឍរាងកាយ សុខភាព និងបញ្ញាស្មារតីដើម្បីរៀនសូត្រ និងធ្វើការងារក្នុងជីវិត។ ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការដៃគូអភិវឌ្ឍន៍នានា និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមមេត្តាចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាកង្វះអាហារូបត្ថម្ភ ដែលវាអាចប៉ះពាល់ការរីកចម្រើនសេដ្ឋកិច្ចនិងសង្គមជាតិយើង។

ទន្ទឹមនឹងនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវឲ្យគ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលបាន និងកំពុងធ្វើការងារលើសុវត្ថិភាពចំណីអាហារ ត្រូវបង្កើនកិច្ចសហការគ្នាឲ្យបានល្អប្រសើរ ដើម្បីធានាថា ទាំងស្បៀងអាហារនាំចូល និងស្បៀងអាហារផលិតនៅក្នុងប្រទេសកម្ពុជា ត្រូវតែមានសុវត្ថិភាពខ្ពស់ និងគុណភាពល្អ ដើម្បីជៀសវាងគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋ និងជាពិសេសដើម្បីការពារកុមារឲ្យជៀសផុតពីជំងឺផ្សេងៗ ដែលនាំឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ។ លទ្ធផលនៃការអង្កេតនាពេលថ្មីៗនេះ បានបង្ហាញថា ៤៣% នៃម្តាយៗនៅរាជធានីភ្នំពេញ បានបំបៅទឹកដោះសិប្បនិម្មិតដល់ទារកអាយុ ០ ដល់ ៦ខែ។ ដូច្នេះ សូមក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ត្រូវតែបន្តនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាធ្វើយុទ្ធនាការអប់រំប្រជាពលរដ្ឋដើម្បីផ្លាស់ប្តូរទម្លាប់ និងឥរិយាបថ និងធ្វើឲ្យប្រជាជនបានយល់ជ្រួតជ្រាបថា **ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ចាប់ពីអាយុ ០ រហូត ដល់អាយុ ៦ខែ គឺជាជម្រើសដ៏ល្អ និងប្រកបដោយសុខុមាលភាព** ជាជាងការបំបៅកូនដោយទឹកដោះសិប្បនិម្មិត និងត្រូវបង្កើតឲ្យមានសហគមន៍ និងមន្ទីរពេទ្យស្រឡាញ់ទារកនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ដោយបញ្ហាកង្វះអាហារូបត្ថម្ភ ក៏មានការទំនាក់ទំនងគ្នាដ៏ជិតស្និទ្ធជាមួយនឹងការប្រើប្រាស់ទឹកស្អាតនិងអនាម័យល្អ រាជរដ្ឋាភិបាលសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវនាំគ្នាប្រើប្រាស់ទឹកបរិភោគប្រកបដោយសុវត្ថិភាព ប្រើប្រាស់បង្គន់អនាម័យជាប្រចាំ និងលាងសម្អាតដៃជាមួយសាប៊ូ ដើម្បីកាត់បន្ថយជំងឺនានាដែលបណ្តាលមកពីការប្រើប្រាស់ទឹកកខ្វក់ និងការរស់នៅគ្មានអនាម័យ។ ការ

ប្រើប្រាស់ចំណីអាហារដែលមានបញ្ចូលមីក្រូសារជាតិសមស្របដូចជា÷ អំបិលអ៊ីយ៉ូត, ទឹកត្រី ទឹកស៊ីអ៊ីវដែលមានជាតិដែក គឺជាវិធានការដ៏មានប្រសិទ្ធភាព ដែលរាជរដ្ឋាភិបាល សូមលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន នៅក្នុងការរស់នៅប្រចាំថ្ងៃ។

នៅក្នុងស្មារតីនិងកិច្ចខិតខំប្រឹងប្រែងអនុវត្តលើការងារទាំងអស់នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំមានជំនឿនិងក្តីសង្ឃឹមយ៉ាងមុតមាំថាស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជានឹងមានភាពប្រសើរឡើង ហើយតាមរយៈការរៀបចំ **ទិវាជាតិអាហារូបត្ថម្ភលើកទី១** នេះ នឹងធ្វើឱ្យជនរួមជាតិយើងកាន់តែយល់ដឹងច្បាស់ និងចូលរួមកែលម្អស្ថានភាពអាហារូបត្ថម្ភឱ្យកាន់តែល្អ ដើម្បីជីវិតរស់នៅកាន់តែប្រសើរ។

ជាទីបញ្ចប់ ដើម្បីចូលរួមអបអរសាទរ **ទិវាជាតិអាហារូបត្ថម្ភ ៦ វិច្ឆិកា** និងចូលរួមសប្បាយរីករាយក្នុងព្រះរាជពិធី**បុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក** ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ប្រគេនពរព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៤

**ហ៊ុន សែន**